**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :...........០៣១/២២..........ក.ប/ស.ជ.ល.ម.ហ

# សេចក្តីជូនដំណឹង

# ស្តីពី

# ការធ្វើតេស្តភាសាជប៉ុន JFT-Basic សម្រាប់ពលករជំនាញ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថាអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តភាសាជប៉ុន JFT-Basic តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ក្នុងគម្រោងពលករជំនាញ ដែលមានព័ត៌មានលម្អិត ដូចខាងក្រោម៖

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ភាសាជប៉ុន<br>JFT-Basic | ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២<br>ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២<br>ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២<br>ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២២<br>ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២២<br>ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ | - សកលវិទ្យាល័យអន្តរជាតិប៊ែលធី (សាខាទួលស្លែង)<br>- វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI) | ២២ដុល្លារ |

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តភាសាជប៉ុន JFT-Basic គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលមើលគេហទំព័រ http://ac.prometric-jp.com/testlist/nc/en/index.html ឬទំនាក់ទំនងតាមលេខទូរស័ព្ទ +855 10 568 383/ +855 17 571 177/ +855 97 767 0033 រៀងរាល់ម៉ោងធ្វើការ
- ព័ត៌មានមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖

  ១. សកលវិទ្យាល័យអន្តរជាតិ ប៊ែលធី (សាខាទួលស្លែង)
  - អាសយដ្ឋាន៖ ផ្ទះលេខ២១ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
  - លេខទូរស័ព្ទ៖ +855 78 221 222

  ២. វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
  - អាសយដ្ឋាន៖ ផ្ទះលេខ៩A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
  - លេខទូរស័ព្ទ៖ +855 12 629 768 / +855 15 729 123

- សេវានៃការចុះឈ្មោះធ្វើតេស្តគឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន
- **ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្ត៖** អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ

**បញ្ជាក់៖** កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជំងឺកូវីដ-១៩។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញសម្រាប់ផ្នែកថែទាំ ជ្រាបតាមការគួរ។

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
-ឯកសារ-កាលប្បវត្តិ